

# មុខងារ Find My Device លើទូរស័ព្ទ Android

កាលបរិច្ឆេទ 31/01/2023

DigitalHub101

# ហេតុអ្វីបានជាមុខងារនេះមានសារសំខាន់?

ប្រសិនបើទូរស័ព្ទអ្នកបាត់ ឬត្រូវបានគេលួច មុខងារ Find My Device អាចជួយស្វែងរកទូរស័ព្ទដែលបាត់ ដោយអនុញ្ញាតឱ្យ អ្នកអាចតាមដានទីតាំងទូរស័ព្ទនោះពីចម្ងាយ ចាក់សោទូរស័ព្ទពីចម្ងាយ និងអាចលុបទិន្នន័យចេញពីទូរស័ព្ទដែលបាត់នោះពីចម្ងាយបានទៀតផង។

ដើម្បីអាចប្រើមុខងារនេះបាន អ្នកប្រើប្រាស់ត្រូវបើកមុខងារនេះនៅលើទូរស័ព្ទពួកគេជាមុន ហើយទូរស័ព្ទនោះត្រូវបើកមុខងារបង្ហាញទីតាំង ទូរស័ព្ទនោះនៅបើកដំណើរការធម្មតា (មិនបិទ ឬមិនអស់ថ្ម) និងកំពុងភ្ជាប់ទៅកាន់អ៊ីនធឺណិតដែរ។

DigitalHub101

# របៀបបើកមុខងារ Find My Device លើទូរស័ព្ទ

- ចូលទៅកាន់ Settings > Security > **Find My Device**
- ចុចលើ Find My Device > On ដើម្បីបើកមុខងារនេះ




DigitalHub101

# របៀបប្រើមុខងារ Find My Device លើកម្មវិធីរុករក

- ចូលទៅកាន់គេហទំព័រ android.com/find

*អ្នកនឹងតម្រូវឱ្យបញ្ចូលអ៊ីមែល និងពាក្យសម្ងាត់អ៊ីមែល នៃគណនី Google (Gmail Account) ដែលបានប្រើជាមួយទូរស័ព្ទដែលបាត់នោះ។*




ទីតាំងនេះជាទីតាំង បច្ចុប្បន្នភាពដែលទូរស័ព្ទអ្នកកំពុងស្ថិតនៅ។ ករណីទូរស័ព្ទអ្នកបិទ អស់ថ្ម ឬមិនបានភ្ជាប់ទៅកាន់អ៊ីនធឺណិត អ្នកនៅតែអាចមើលឃើញប្រវត្តិទីតាំងចុងក្រោយគេរបស់ទូរស័ព្ទដែរ។

DigitalHub101

# មុខងារ Play Sound, Secure Device និង Erase Device

ចុចលើពាក្យ
PLAY SOUND
ទូរស័ព្ទអ្នកនឹងរោទ៍
រយៈពេល៥នាទី
ទោះបីជាអ្នកបាន
ដាក់សំឡេងស្ងាត់
ក៏ដោយ។




ចុចលើ
SECURE DEVICE
ដើម្បីចាក់សោទូរស័ព្ទ
អ្នក។ បើទូរស័ព្ទនោះ
មិនទាន់មានលេខកូដ
សម្ងាត់ការពារទេ
អ្នកអាចបង្កើត
លេខកូដសម្ងាត់ថ្មី
ពីចម្ងាយបាន។

ចុចលើ
ERASE DEVICE
នោះទិន្នន័យ និង
កម្មវិធីដែលបាន
ដំឡើងក្នុងទូរស័ព្ទ
របស់អ្នក នឹង
លុបចេញពី
ទូរស័ព្ទនោះ។

DigitalHub101